ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនប្រជាពលរដ្ឋ រស់នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប

រដ្ឋបាលខេត្តសៀមរាប មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងសៀមរាប ជ្រាបថា អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលខេត្តសៀមរាប នឹងរៀបចំចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ ជូនដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងសៀមរាប រយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ នៅតាមទីតាំងដែលបានកំណត់ចំនួន ៣៨ ទីតាំង ពេលព្រឹកចាប់ពីម៉ោង ៨:០០ ដល់ម៉ោង ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:០០ នាទី ដូចមានក្នុងតារាងជូនភ្ជាប់មកជាមួយ។

សូមបងប្អូនប្រជាពលរដ្ឋដែលត្រូវចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ភ្ជាប់មកជាមួយនូវឯកសារ (ច្បាប់ដើម ឬថតចម្លង) អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬលិខិតបញ្ជាក់ពីអាជ្ញាធរ ហើយត្រូវអនុវត្តឲ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត នូវគោលការណ៍ណែនាំ និងវិធានការនានារបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ពិសេសអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣ការពារ និង៣កុំ" និងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយឲ្យបានល្អប្រសើរ។

សូមបញ្ជាក់ថា ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ រយៈពេល១៤ថ្ងៃនេះ សម្រាប់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងសៀមរាបតែប៉ុណ្ណោះ ចំពោះបងប្អូនប្រជាពលរដ្ឋរស់នៅតាមបណ្តាស្រុកនឹងត្រូវចាក់នៅពេលបន្ទាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងសៀមរាប អញ្ជើញស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ តាមពេលវេលាកំណត់ខាងលើ នៅតាមទីតាំងដែលរដ្ឋបាលខេត្តបានកំណត់។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅខេត្តសៀមរាប ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១
**រដ្ឋបាលខេត្តសៀមរាប**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាខេត្តសៀមរាប

"ដើម្បីសូមគោរពជូនជ្រាប"
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- រដ្ឋបាលក្រុងសៀមរាប

"ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប

# ទីតាំងចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដំណាក់កាលទី២ ជុំទី១
# ក្នុងក្រុងសៀមរាប ខេត្តសៀមរាប
# ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២១

-ពេលព្រឹក ៖ ចាប់ពីម៉ោង ៨:០០ នាទី ដល់ម៉ោង ១១:៣០ នាទី
-ពេលរសៀល ៖ ចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:០០ នាទី

| ល.រ | ទីតាំងចាក់វ៉ាក់សាំង | រយៈពេល | ផ្សេងៗ |
|---|---|---|---|
| | **១. សង្កាត់គោកចក** | | |
| ១ | វត្តសណ្ដាន់ | ១៤ ថ្ងៃ | |
| ២ | សាលាបឋមសិក្សា ភូមិជ័យ | ១៤ ថ្ងៃ | |
| ៣ | សាលាបឋមសិក្សា គោកដូង | ១៤ ថ្ងៃ | |
| | **២. សង្កាត់សាលាកំរើក** | | |
| ៤ | សាលាបឋមសិក្សា វត្តដំណាក់ | ១៤ ថ្ងៃ | |
| ៥ | សាលាបឋមសិក្សា វត្តបូព៌ | ១៤ ថ្ងៃ | |
| ៦ | សាលាវិទ្យាល័យ ហ៊ុនសែន វត្តស្វាយ | ១៤ ថ្ងៃ | |
| | **៣. សង្កាត់ជ្រាវ** | | |
| ៧ | សាលាបឋមសិក្សា ជ្រាវ | ១៤ ថ្ងៃ | |
| ៨ | សាលាបឋមសិក្សា ខ្នារចាស់ | ១៤ ថ្ងៃ | |
| ៩ | សាលាបឋមសិក្សា តាពេជ្រ | ១៤ ថ្ងៃ | |
| | **៤. សង្កាត់ចុងឃ្នៀស** | | |
| ១០ | សាលាអនុវិទ្យាល័យ ចុងឃ្នៀស | ១៤ ថ្ងៃ | |
| ១១ | សាលាបឋមសិក្សា ចុងឃ្នៀស | ១៤ ថ្ងៃ | |

សាលាខេត្តសៀមរាប ផ្លូវ៦០ម៉ែត្រ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Provincial Hall, 60m Street, Boeng Donpa Village, Sangkat Slakram, Siem Reap Municipality, Siem Reap Province, Email: srphall@yahoo.com Tel: (855) 63 765 276, (855) 63 765 319, Fax: (855) 63 765 343

| | | | |
|---|---|---|---|
| ៥. សង្កាត់គោកចក | | | |
| ១២ | វត្តប្រាសាទគោកចក | ១៤ ថ្ងៃ | |
| ៦.សង្កាត់នគរធំ | | | |
| ១៣ | សាលាបឋមសិក្សា ក្រវ៉ាន់ | ១៤ ថ្ងៃ | |
| ១៤ | សាលាបឋមសិក្សា សាមគ្គីសហគមន៍ គួតាំតាអញ្ញាញ | ១៤ ថ្ងៃ | |
| ៧.សង្កាត់សៀមរាប | | | |
| ១៥ | សាលាអនុវិទ្យាល័យ ពោធិ៍បន្ទាយជ័យ | ១៤ ថ្ងៃ | |
| ១៦ | សាលាវិទ្យាល័យ អារញ្ញសាគរ CFC | ១៤ ថ្ងៃ | |
| ១៧ | មណ្ឌលសុខភាពសៀមរាប | ១៤ ថ្ងៃ | |
| ១៨ | សាលាបឋមសិក្សា គង់ម៉ុច | ១៤ ថ្ងៃ | |
| ១៩ | សាលាបឋមសិក្សា ភ្នំក្រោម ស៊ុន | ១៤ ថ្ងៃ | |
| ៨.សង្កាត់ស្រង៉ែ | | | |
| ២០ | សាលាបឋមសិក្សា ភូមិថ្នល់ | ១៤ ថ្ងៃ | |
| ២១ | សាលាបឋមសិក្សា ព្រៃធំ | ១៤ ថ្ងៃ | |
| ៩.សង្កាត់សំបួរ | | | |
| ២២ | សាលាបឋមសិក្សា សំបួរ | ១៤ ថ្ងៃ | |
| ១០.សង្កាត់ក្របីរៀល | | | |
| ២៣ | សាលាអនុវិទ្យាល័យ ក្របីរៀល | ១៤ ថ្ងៃ | |
| ២៤ | សាលាបឋមសិក្សា ព្រៃទទឹង | ១៤ ថ្ងៃ | |
| ២៥ | ផ្សារគោរស់ | ១៤ ថ្ងៃ | |
| ១១.សង្កាត់ស្លក្រាម | | | |
| ២៦ | សាលាបឋមសិក្សា បន្ទាយចាស់ | ១៤ ថ្ងៃ | |
| ២៧ | សាលាអនុវិទ្យាល័យមិត្តភាពខ្មែរ ជប៉ុន ឥន្ទកោសា | ១៤ ថ្ងៃ | |
| ២៨ | សាលាបឋមសិក្សា ឆ្លកអណ្ដូង | ១៤ ថ្ងៃ | |
| ២៩ | សាលាបឋមសិក្សា ពោធិលង្កា | ១៤ ថ្ងៃ | |
| ១២.សង្កាត់ស្វាយដង្គំ | | | |
| ៣០ | មន្ទីរពេទ្យបង្អែកខេត្តសៀមរាប | ១៤ ថ្ងៃ | |
| ៣១ | មន្ទីរពេទ្យបង្អែកខេត្តសៀមរាប | ១៤ ថ្ងៃ | |

| | | | |
|---|---|---|---|
| ៣២ | មណ្ឌលសុខភាពមណ្ឌល១ | ១៤ ថ្ងៃ | |
| ៣៣ | វត្តកេសរារាម | ១៤ ថ្ងៃ | |
| ៣៤ | វត្តកេសរារាម | ១៤ ថ្ងៃ | |
| ៣៥ | សាលាបឋមសិក្សា ស្វាយដង្គំ | ១៤ ថ្ងៃ | |
| ៣៦ | សាលាបឋមសិក្សា ជាស៊ីម | ១៤ ថ្ងៃ | |
| ៣៧ | សាលាបឋមសិក្សា វត្តចក | ១៤ ថ្ងៃ | |
| ៣៨ | សាលាបឋមសិក្សា វត្តចក | ១៤ ថ្ងៃ | |

**សរុបចំនួន ១២ សង្កាត់ និង ៣៨ ទីតាំង**

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅខេត្តសៀមរាប ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

**រដ្ឋបាលខេត្តសៀមរាប**